# II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

## អនុក្រឹត្យលេខ ១៩ អនក្រ.បក

## ស្តីពីការលុបនាទីឡូត៍នេសាទ

## និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ

## ខេត្តបន្ទាយមានជ័យ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣.ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា [illegible].-**

វិបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និង កន្លែងដាក់ទាទបំរុងទុកនៅទឹកសាប ក្នុងខេត្តបន្ទាយមានជ័យ ដូចតទៅ :

លុបចេញនាទីឡូត៍នេសាទលេខ៣ និងលេខ៤ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅដោយរក្សាទុកអន្លង់ត្រីមេពូជដូចខាងក្រោម :

ឡូត៍នេសាទលេខ ៣ រក្សាទុកអន្លង់ត្រីមេពូជមួយកន្លែងត្រង់ចំនុចវត្តតាសល់ ក្នុងឃុំគោកបាឡាំង ដែលមានចំងាយសងខាងវត្តមួយគីឡូម៉ែត្រផ្នែកខាងលើ និងមួយគីឡូម៉ែត្រផ្នែកខាងក្រោម ដែលមានផ្ទៃក្រឡាសរុប ៩ ហិកតា ។

ឡូត៍នេសាទលេខ ៤ រក្សាទុកអន្លង់ត្រីមេពូជនៅត្រង់ចំនុចវត្តភ្លៀត ក្នុងភូមិភ្លៀត និងអន្លង់វត្តកោះ ។ អន្លង់ទាំងពីរនេះត្រូវរក្សាការពារ ចាប់ពីមាត់អន្លង់តាមបណ្ដោយដងស្ទឹងទៅខាងលើ ២០០ម និងពីមាត់អន្លង់ទៅខាងក្រោម ២០០ម ដែលមានផ្ទៃក្រឡាសរុប ៤ ហិកតា ។

- កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តបន្ទាយមានជ័យ និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តបន្ទាយមានជ័យ ដែលត្រូវលុប និងកាត់បន្ថយ**

ឯកតា (ហិកតា)

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍នេសាទ | ផ្ទៃឡូត៍កាត់ចេញ | ផ្ទៃឡូត៍នៅសល់ | ផ្ទៃឡូត៍កាត់គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ១២.៩១៦ | ១១.៧៣៨ | ១.១៧៨ | ៩០.៨៨ | |
| ២ | ៥.៣៤៣ | ១២៣ | ៥.២២០ | ២.៣០ | |
| ៣ | ៧.៤៧០ | ៧.៤៦១ | ៩ | ៩៩.៨៧ | លុបចេញ រក្សាទុក ៩ ហ.ត |
| ៤ | ៧.០២៧ | ៧.០២៣ | ៤ | ៩៩.៩៤ | លុបចេញ រក្សាទុក ៤ ហ.ត |
| សរុប ៤ | ៣២.៧៥៦ | ២៦.៣៤៥ | ៦.៤១១ | ៨០.៤២ | |

**មាត្រា ២.-**

ដែននេសាទដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនឱ្យជនណាមួយហួងហែងយកទៅលក់ ឬជួលឱ្យឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា ៤ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ២០ អនក្រ.បក

## ស្តីពី

## ការលុបនាទីឡូត៍នេសាទ និងរក្សាទុកដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តក្រចេះ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

***

## រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា